# ស្ថានទូតជប៉ុន
# ប្រចាំព្រះរាជាណាចក្រកម្ពុជា
# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៦

## ជប៉ុនផ្តល់ ២៥៦,៣១៧ ដុល្លារអាមេរិក
## សម្រាប់លើកកម្ពស់ការអប់រំបញ្ចូលគ្នានៅកម្ពុជា

ក្រោមគ្រោងការណ៍នៃជំនួយឥតសំណង សម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន រដ្ឋាភិបាលជប៉ុន ផ្តល់ថវិកាចំនួន ២៥៦,៣១៧ដុល្លារអាមេរិក ដល់អង្គការសមាគមន៍សម្រាប់ជំនួយ និងសង្គ្រោះនៃប្រទេសជប៉ុន (អង្គការAARជប៉ុន)។ កិច្ចសន្យាផ្តល់ជំនួយ ត្រូវបានចុះហត្ថលេខានៅថ្ងៃនេះ ដោយឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងអ្នកស្រី សូណូដា តូម៉ូកូ នាយិការអង្គការAARជប៉ុន ដើម្បីអនុវត្ត"គម្រោងលើកកម្ពស់ការអប់រំបញ្ចូលគ្នាសម្រាប់កុមារពិការនៅខេត្តកណ្តាល ដំណាក់កាលទី២" នៅស្ថានទូតជប៉ុន។

អង្គការAARជប៉ុន នឹងជួយលើកកម្ពស់ការអប់រំបញ្ចូលគ្នា តាមរយៈការបង្កើតអោយមានជម្រាលសម្រាប់កុមារពិការនៅក្នុងសាលារៀន និងការរៀបចំអោយមានការបណ្តុះបណ្តាលគ្រូបង្រៀនសម្រាប់កុមារពិការ ក្នុងស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល។ ជាមួយនឹងគម្រោងនេះ សិស្សានុសិស្ស និងលោកគ្រូ-អ្នកគ្រូ ព្រមទាំងប្រជាសហគមន៍ប្រមាណជា ៣, ៣០០នាក់ នឹងទទួលបានចំណេះដឹងអំពីពិការភាព ហើយគម្រោងនេះ រំពឹងថា នឹងនាំអោយអត្រានៃការចុះឈ្មោះចូលរៀនរបស់កុមារពិការមានចំនួនកើនឡើង។

កម្មវិធីជំនួយឥតសំណង សម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន បានចាប់ផ្តើមនៅប្រទេសកម្ពុជាតាំងពីឆ្នាំ២០០២ ដើម្បីគាំទ្រដល់សកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីជួយដល់ការអភិវឌ្ឍ និងស្តាបនាប្រទេសកម្ពុជាឡើងវិញនៅតាមកំរិតមូលដ្ឋាន។ ចាប់តាំងពីឆ្នាំ២០០២មករដ្ឋាភិបាលជប៉ុន បានផ្តល់ថវិកាជាង ២៦.១លានដុល្លារអាមេរិក ដល់គម្រោងចំនួន ៩៤គម្រោង ដែលផ្តោតសំខាន់ទៅលើវិស័យអប់រំនៅកម្រិតមូលដ្ឋាន វិស័យសុខាភិបាល វិស័យកសិកម្ម និងសកម្មភាពបោសសំអាតមីន។ គម្រោងនេះគឺជាគម្រោងទី១ តាមរយៈគ្រោងការណ៍នៃជំនួយនេះសម្រាប់ឆ្នាំសារពើពន្ធឆ្នាំ២០១៦របស់ជប៉ុន(មេសា២០១៦ ដល់មិនា២០១៧)។

---

*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*
*ទូរសព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០*
*អ៊ីមែល: eco.jpn@.pp.mofa.go.jp*
*គេហទំព័រ: http://www.kh.emb-japan.go.jp*